# គោលការណ៍សង្ខេប

## ការបើកទូលាយទិន្នន័យឧស្សាហកម្មនិស្សារណកម្មនិងបរិស្ថានដើម្បីសេដ្ឋកិច្ចកាន់តែប្រសើរ

សីហា ២០២២

គោលការណ៍សង្ខេបនេះ គឺជាលទ្ធផលនៃកិច្ចពិភាក្សាដែលបានធ្វើឡើងនៅក្នុងសិក្ខាសាលាស្ដីពី «ការបើកទូលាយទិន្នន័យឧស្សាហកម្មនិស្សារណកម្មនិងបរិស្ថានដើម្បីសេដ្ឋកិច្ចកាន់តែប្រសើរ»។ សិក្ខាសាលាមានគោលបំណងដូចជាៈ ១. ពិភាក្សាអំពីការរីកចម្រើននៃឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា និង ២.លើកកម្ពស់ការយល់ដឹងអំពីការរួមចំណែកនៃទិន្នន័យបើកទូលាយ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងការកាត់បន្ថយផលប៉ះពាល់សម្រាប់សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច។

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃឧស្សាហកម្មនិស្សារណកម្មរបស់ប្រទេសកម្ពុជា បានបញ្ចូលការវិនិយោគដ៏ធំនៅក្នុងប្រទេស និងជំរុញការវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផងដែរ។ លើសពីនេះ ការរីកលូតលាស់នៃមូលនិធិសាធារណៈដែលទទួលបានពីវិស័យកំពុងអភិវឌ្ឍន៍នេះអាចនាំមកនូវវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ចយ៉ាងច្រើនសម្រាប់ប្រជាជនកម្ពុជាប្រសិនបើមានការគ្រប់គ្រងបានល្អ។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពទាំងនេះក៏មានទំនោរទៅរកផលប៉ះពាល់សេដ្ឋកិច្ចសង្គម និងបរិស្ថានសំខាន់ៗសម្រាប់សហគមន៍មូលដ្ឋានដែលជាធម្មតាខ្វះឬមានកម្រិតតិចតួចក្នុងការចូលប្រើទិន្នន័យបើកទូលាយទាក់ទងនឹងគុណវិបត្តិ និងភាពរអាក់រអួល។

ដោយពិចារណាលើព័ត៌មានទាំងអស់ដែលបានចែករំលែកនិងពិភាក្សានៅក្នុងសិក្ខាសាលានេះ យើងបានកំណត់អត្តសញ្ញាណនៃបញ្ហាប្រឈមសំខាន់ៗទាក់ទងនឹងបញ្ហាកង្វះតម្លាភាពនាពេលបច្ចុប្បន្ន។ ជាការឆ្លើយតប គោលការណ៍សង្ខេបនេះបង្ហាញពីសំណុំនៃយុទ្ធសាស្ត្រអាទិភាពដែលអាចលើកកម្ពស់តម្លាភាពទិន្នន័យ និងកាត់បន្ថយផលប៉ះពាល់នៃឧស្សាហកម្មនិស្សារណកម្មនិងការរិចរិលបរិស្ថាន។

## បញ្ហាប្រឈម

**(១)** ទោះបីជាច្បាប់មួយចំនួនដូចជា ច្បាប់ស្ដីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ស្នើឱ្យរាជរដ្ឋាភិបាលត្រូវផ្សព្វផ្សាយព័ត៌មានដល់សាធារណៈ ប៉ុន្តែរហូតមកដល់ថ្ងៃនេះ **មិនទាន់មានច្បាប់ជាក់លាក់ណាមួយ** ដែលបញ្ជាក់ជាផ្លូវការអំពីកាតព្វកិច្ចនេះទេ។ របាយការណ៍និងការត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតែដំណើរការក្នុងភាពស្រអាប់ហើយជាលទ្ធផលអំពីពុករលួយបានរារាំងការបោះពុម្ពផ្សាយនៃរបាយការណ៍ទាំងនេះ។

**(២)** ទោះបីជាលទ្ធផលនៃការរៀបចំកិច្ចពិភាក្សាសាធារណៈដើម្បីផ្ដល់មតិកែលម្អលើរបាយការណ៍វាយ តម្លៃហេតុប៉ះពាល់បរិស្ថាន ប្រជាពលរដ្ឋក៏ដូចជាអ្នកសារព័ត៌មាន និងក្រុមអង្គការសង្គមស៊ីវិលប្រឈមនឹង**ឧបសគ្គក្នុងការឈ្វេងយល់អំពីទិដ្ឋភាពបច្ចេកទេសនៃការរាស់វែងផ្នែកសង្គមនិងបរិស្ថាននៅក្នុងរបាយការណ៍**។ ដូចគ្នានេះដែរ ជាមួយនឹងកម្រិតនៃការចូលទៅប្រើប្រាស់របាយការណ៍ សាធារណជនមិនអាចចូលរួមក្នុងការចូលរួមជាសាធារណៈដើម្បីស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ និងទាមទារអ្វីដែលពួកគេសមនឹងទទួលបានពីផលប៉ះពាល់នៃគម្រោងវិនិយោគ។

**(៣)** ជាធម្មតា សហគមន៍មូលដ្ឋាន**មានកម្រិតក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត** ដែលមានន័យថាពួកគេខ្វះព័ត៌មានទាក់ទងនឹងការជីកយករ៉ែ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលឆ្លុះបញ្ចាំងពីភាពរអាក់រអួល ដែលសកម្មភាពទាំងនេះអាចបង្កផលប៉ះពាល់ដល់ដីធ្លីនិងបរិស្ថានរបស់ពួកគេ។ ជាការពិតណាស់ ប្រជាពលរដ្ឋជាច្រើនមិនបានស្គាល់សិទ្ធិរបស់ពួកគេក្នុងការទទួលបានព័ត៌មានសាធារណៈនោះឡើយ។

**(៤)** អ្នកសារព័ត៌មានជាច្រើនមិនបង្ហាញចំណាប់អារម្មណ៍លើឧស្សាហកម្មនិស្សារណកម្មទេ។ ដូច្នេះ ពួកគេមិនធ្វើការឆ្ពោះទៅរកការផ្សព្វផ្សាយទិន្នន័យសំខាន់ៗទាក់ទងនឹងប្រធានបទឡើយ។ ជាងនេះទៅទៀត អ្នកសារព័ត៌មានជាន់ខ្ពស់ជាច្រើនធ្វើការឱ្យវិស័យឯកជន ហើយមិនមានសេរីភាពក្នុងការសរសេរអត្ថបទអំពីទិន្នន័យបើកទូលាយនិងកំណែទម្រង់សង្គមនោះឡើយ។



# អនុសាសន៍អាទិភាព

**១. ចូលរួមជាមួយភាគីពាក់ព័ន្ធក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត** រួមមានរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូរអភិវឌ្ឍន៍ និងប្រជាពលរដ្ឋ។ នេះគឺជាកន្លែងដែលបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងចូលរួមចំណែកក្នុងការបង្កើតធនធានឌីជីថល និងធានាថាប្រជាពលរដ្ឋមានព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងការអភិវឌ្ឍ និងដំណោះស្រាយដែលមាន។

**២. អនុវត្តសេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន** ដែលនឹងផ្ដល់លទ្ធភាពឱ្យប្រជាជនកម្ពុជា ទទួលបានព័ត៌មានកាន់តែមានប្រសិទ្ធភាពពីស្ថាប័នសាធារណៈទាក់ទងជាមួយនឹងការប្រើប្រាស់មូលនិធិសាធារណៈ របៀបដែលការសម្រេចចិត្តប៉ះពាល់ដល់សហគមន៍ និងបញ្ហាផ្សេងទៀតដែលប៉ះពាល់ដល់ជីវិតនិងសុខុមាលភាពរបស់ពួកគេ។ ជាការពិតណាស់ សិទ្ធិទទួលបានព័ត៌មានបានចែងថាស្ថាប័នសាធារណៈពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិមានកាតព្វកិច្ចចែករំលែកព័ត៌មានទាំងអស់ ដោយមិនរាប់បញ្ចូលព័ត៌មានសម្ងាត់។ ព័ត៌មានគួរត្រូវបានបង្ហោះនៅលើគេហទំព័រ និងផ្សព្វផ្សាយក្នុងប៉ុស្ដិ៍ទូរទស្សន៍។

**៣. បង្កើតការសន្ទនា ឬព្រឹត្តិការណ៍បន្ថែមទៀត ដើម្បីលើកកម្ពស់ការយល់ដឹង និងចូលរួមក្នុងប្រព័ន្ធផ្សព្វផ្សាយបន្ថែមទៀត** ដើម្បីតាមដាននិងរាយការណ៍អំពីឧស្សាហកម្មនិស្សារណកម្ម។ វេទិកាបែបនេះគួរតែត្រូវបានប្រើដើម្បីបង្ហាញពីកង្វល់ និងការទាមទារពីសហគមន៍មូលដ្ឋាននិងលើកទឹកចិត្តអ្នកសារព័ត៌មានឱ្យដោះស្រាយបញ្ហាបែបនេះ។

**៤. អំពាវនាវឱ្យមានការផ្សព្វផ្សាយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ** ដោយពង្រឹងសកម្មភាពរួមគ្នារវាងដៃគូអភិវឌ្ឍន៍ ជាមួយនិងអ្នកសារព័ត៌មាន។ ភាគីពាក់ព័ន្ធគួរកំណត់សកម្មភាព និងយុទ្ធសាស្ត្រ ដើម្បីទាមទារឱ្យមានការចែករំលែកព័ត៌មានបន្ថែមទៀតដល់រដ្ឋាភិបាល និងក្រុមហ៊ុនឯកជន។

**៥. បង្កើនជំនាញទិន្នន័យ និងឌីជីថលរបស់បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ។** កម្មវិធីបណ្ដុះបណ្ដាលបន្ថែមលើ**សារព័ត៌មានដែលជំរុញដោយទិន្នន័យ** នឹងផ្ដល់សិទ្ធិអំណាចដល់អ្នកជំនាញផ្នែកព័ត៌មាន និងផ្ដល់ឱ្យពួកគេនូវជំនាញដែលត្រូវការដើម្បីចងក្រង វិភាគ និងបង្ហាញទិន្នន័យលើទម្រង់ដែលងាយស្រួលប្រើ។ តាមរយៈការធានាថា អ្នកសារព័ត៌មានមានការបកស្រាយគ្រប់គ្រាន់នៃទិន្នន័យនិងព័ត៌មាននឹងធ្វើឱ្យប្រសើរឡើងដោយផ្ទាល់នូវប្រព័ន្ធអេកូព័ត៌មាននៅកម្ពុជា។

**៦.ធានាថាសហគមន៍មូលដ្ឋានមានសិទ្ធិចូលប្រើទិន្នន័យដែលមានដោយមិនពន្យារពេល ក្នុងទម្រង់ពេលវេលានិងងាយស្រួលប្រើ។** អាស្រ័យហេតុនេះ ដើម្បីនាំយកព័ត៌មានទៅជិតប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ខ្លឹមសារដែលពាក់ព័ន្ធបំផុតគួរតែត្រូវបានបង្ហាញជា**វីដេអូនិងព័ត៌មានក្រាហ្វិក** ដូច្នេះពួកគេអាចយល់និងប្រើប្រាស់វាយ៉ាងងាយស្រួល។ សំខាន់ជាងនេះ ការផ្សព្វផ្សាយអាចត្រូវបានបង្កើនដោយការផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្ដាញប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដូចជា Facebook និង YouTube ។

*គោលការណ៍សង្ខេបនេះផលិតដោយ៖*

អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia

*សហការណ៍ជាមួយ៖*

CIPA

*គោលការណ៍សង្ខេបនេះគាំទ្រដោយ* ***មូលនិធិហេនរេចបូល។***

HEINRICH BÖLL STIFTUNG
ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

**អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)**

*(+855) 23 902 196*
*contact@opendevcam.net*
*www.opendevelopmentcambodia.net*
*@OpenDevCam*
*@OpenDevCam*

CC BY SA